ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
លេខាធិការដ្ឋានរដ្ឋបាលសរុប
ការិយាល័យសរុបផែនការ

# សូមគោរពជូន
## លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

**តាមរយៈ÷** -លោកប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប
**-លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជ.ប.ជ**

**កម្មវត្ថុ÷** របាយការណ៍ស្តីពី ពិធីប្រកាសផ្សព្វផ្សាយផែនការយុទ្ធសាស្រ្តជាតិ ឆ្នាំ២០២៤-២០២៨ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ ខ្ញុំបាទសូមគោរពជម្រាបជូន លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មេត្តាជ្រាបថា៖ នៅព្រឹកថ្ងៃព្រហស្បតិ៍ ១២រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស២៥៦៨ ត្រូវនឹងថ្ងៃទី ០១ ខែសីហា ឆ្នាំ២០២៤ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានរៀបចំពិធីប្រកាសផ្សព្វផ្សាយផែនការយុទ្ធសាស្រ្តជាតិ ឆ្នាំ ២០២៤-២០២៨ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញ ដូរមនុស្ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** ។

### I. សមាសភាពចូលរួម

- ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- ឯកឧត្តម **ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ឯកឧត្តម **សាម៉ឺឌី ស៊ីវឌ្ឍនា** រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា
- ឯកឧត្តម **សៅ សុភៈ** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- លោកជំទាវ **ហ៊ូ សាមិត្ត** រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី
- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ជីវ ផល្លី** អគ្គស្នងការរងនគរបាលជាតិ

ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ដែលជាសមាជិក គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ អង្គទូតនានាប្រចាំព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម លោកជំទាវ អគ្គនាយក អគ្គនាយករង តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ឯកឧត្តម លោកជំទាវ អភិបាល អភិបាលរង ស្នងការ ស្នងការរង រាជធានី/ខេត្ត តំណាងអង្គការសង្គមស៊ីវិលដៃគូជាតិ អន្តរជាតិ និងមន្ត្រីបច្ចេកទេស សរុបចំនួនប្រមាណ៖ **៤៥០**រូប ស្រី **១១០**រូប ។

### II. មតិស្វាគមន៍ និងរបាយការណ៍សង្ខេប

ជាកិច្ចចាប់ផ្តើម **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ **គ.ជ.ប.ជ** បានមានមតិស្វាគមន៍ និងរបាយការណ៍សង្ខេប អំពីផែនការយុទ្ធសាស្រ្តជាតិ ៥ឆ្នាំបន្ត ២០២៤-២០២៨ **ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** ជូន **ឯកឧត្តម អភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** និងអង្គពិធីទាំងមូលបានជ្រាបព្រមទាំងបានគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះវត្តមានដ៏ឧត្តុង្គឧត្តម **ឯកឧត្តមអភិសន្តិបណ្ឌិត** ឧបនាយក

រដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ ព្រមទាំងអង្គពិធីទាំងមូលផងដែរ។ **លោកជំទាវ** បានមានប្រសាសន៍បន្តថា ឆ្នាំ២០២៤នេះ គឺជាការរៀបចំ ផែនការយុទ្ធសាស្ត្រជាតិ លើកទី៤ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលកន្លងមក យើងមានផែនការយុទ្ធសាស្ត្រជាតិ ឆ្នាំ២០១១-២០១៣, ២០១៤-២០១៨, ២០១៩-២០២៣ និង៥ឆ្នាំបន្ត ២០២៤-២០២៨។

**លោកជំទាវ** បន្តទៀតថា ការបង្កើតផែនការយុទ្ធសាស្ត្រជាតិ ត្រូវផ្អែក លើមូលដ្ឋានបង្អែកមួយចំនួនដូចជា លិខិតូបករណ៍ជាតិ អន្តរជាតិដែលមានស្រាប់ យន្តការជាតិ អន្តរជាតិ រួមទាំងថ្នាក់អនុតំបន់ (មេគង្គ មេគង្គ-ឡាងឆាង ថ្នាក់តំបន់ (អាស៊ាន Bali Process) និងថ្នាក់ពិភពលោកលោក (GCM) ជាដើម។ ក្រៅពីនោះយើង ផ្អែកលើលទ្ធផលនៃការតាមដានវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣ លទ្ធផលនៃការ វិភាគស្ថានភាពនយោបាយ សង្គម សេដ្ឋកិច្ច ច្បាប់ ការវិវឌ្ឍនៃការប្រើប្រាស់បច្ចេកវិទ្យា និងការវិភាគលើនិន្នាការ និងទម្រង់នៃឧក្រិដ្ឋកម្មជួញដូរមនុស្ស ព្រមទាំងបណ្ដាធាតុចូលដែលផ្ដល់ដោយអ្នកអនុវត្តផ្ទាល់ តំណាងក្រសួង ស្ថាប័ន និងអង្គការដៃគូជាតិ អន្តរជាតិ។ល។

**លោកជំទាវ** ក៏បានបញ្ជាក់ជូនអង្គពិធីអំពី ទស្សនវិស័យ គោលដៅ និងគោលបំណង នៃផែនការយុទ្ធសាស្ត្រជាតិ គឺដើម្បីកម្ពុជាមានសន្តិភាព សមភាព យុត្តិធម៌ និងការអភិវឌ្ឍប្រកបដោយសក្ដានុពល គោលដៅគឺដើម្បីលុបបំបាត់រាល់ទម្រង់ចាស់ថ្មីនៃអំពើជួញដូរមនុស្ស និងធានាឱ្យមានប្រព័ន្ធសុវត្ថិភាពសង្គម ដើម្បីការបង្ការទប់ស្កាត់ភាពរងគ្រោះឱ្យមានប្រសិទ្ធភាព ការអនុវត្តច្បាប់ដែលមានឥទ្ធិពល និងការផ្ដន្ទាទោសយ៉ាងសុក្រឹតចំពោះបទល្មើសជួញដូរមនុស្ស។

ជាថ្មីម្ដងទៀត **លោកជំទាវ** បានមានប្រសាសន៍ថ្លែងអំណរគុណ និងគោរពជូនពរ ជូនចំពោះ **ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** ព្រមទាំង ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងអង្គពិធីទាំងមូល សូមជួបនូវ ពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

## III. ប្រសាសន៍សំណេះសំណាល និងអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់

**ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** មានប្រសាសន៍សំណេះសំណាលក្នុង ពិធីប្រកាសផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រជាតិ ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៤-២០២៨ និងកិច្ចស្វាគមន៍ យ៉ាងកក់ក្ដៅជូនចំពោះ ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ អភិបាល អភិបាលរងរាជធានី ខេត្ត ឯកឧត្តម លោកជំទាវតំណាង អង្គទូតនានា តំណាងអង្គការដៃគូជាតិ អន្តរជាតិ សមាជិក សមាជិកា និងភ្ញៀវ កិត្តិយស ដែលបានអញ្ជើញ មកចូលរួមក្នុងកម្មវិធីនាពេលនេះ។

**ឯកឧត្តមអភិសន្តិបណ្ឌិត** បានមានប្រសាសន៍លើកឡើងថា ផែនការយុទ្ធសាស្ត្រជាតិ ស្ដីពីការប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ ២០២៤-២០២៨ គឺជាផែនទីបង្ហាញផ្លូវសម្រាប់ការគ្រប់គ្រងតាមបណ្ដាក្រសួង ស្ថាប័ន អង្គភាព ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សមាជិកនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស (គ.ជ.ប.ជ) អនុវត្តសកម្មភាពដោយមានផែនការគ្រោងទុកជាមុន សមស្របទៅនឹងស្ថានភាពជាក់ស្ដែង ប្រកបដោយប្រសិទ្ធភាពខ្ពស់។ យើងចង់ឃើញលទ្ធផលដែលសម្រេចបានក្នុងរយៈ៥ឆ្នាំខាងមុខ ដូច្នេះយើងត្រូវមានការវាយតម្លៃជារៀងរាល់ឆ្នាំ ដើម្បីតាមដានវឌ្ឍនភាពនៃកិច្ចប្រតិបត្តិការ ភាពប្រែប្រួលនៃបទល្មើស បញ្ហាប្រឈម និងវិធានការដ៏មានប្រសិទ្ធភាព ដែលអាចឱ្យយើងសម្រេចបានលទ្ធផលទៅតាមគោលដៅដែល បានរំពឹងទុក ដូចដែលមានចែងក្នុងផែនការយុទ្ធជាតិនេះស្រាប់។

**ឯកឧត្តមអភិសន្តិបណ្ឌិត** បានសំដែងនូវការកោតសរសើរយ៉ាងក្រៃលែង ចំពោះការខិតខំប្រឹងប្រែងរបស់ អគ្គលេខាធិការដ្ឋាន នៃ គ.ជ.ប.ជ ក្រោមការដឹកនាំសម្របសម្រួលដោយលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួង

មហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដែលបានចូលរួម និងដឹកនាំកិច្ចប្រជុំជាលក្ខណៈបច្ចេក ទេសច្រើនលើកច្រើនសារជាមួយថ្នាក់ដឹកនាំ និងមន្ត្រីជំនាញតាមបណ្តា ក្រសួង ស្ថាប័ន តំណាង អង្គការ សហប្រជាជាតិ អង្គការដៃគូជាតិ អន្តរជាតិ អង្គការសង្គមស៊ីវិល និងជាមួយក្រុមធ្លាប់រងគ្រោះ រហូតសម្រេច បានការរៀបចំ ផែនការយុទ្ធសាស្ត្រជាតិ ឆ្នាំ២០២៤-២០២៨ នេះឡើង។

**ឯកឧត្តមអភិសន្តិបណ្ឌិត** មានប្រសាសន៍បន្តថា អំពើជួញដូរមនុស្ស ជាឧក្រិដ្ឋកម្មដ៏ស្មុគស្មាញ មួយនៅក្នុងសង្គម ដែលបានបំផ្លាញទាំងធនធានមនុស្ស និងសេចក្តីសុខក្សេមក្សាន្តរបស់មនុស្សគ្រប់វ័យ។ ដូច្នេះកម្ពុជាខ្លួនឯងត្រូវពង្រឹងការគ្រប់គ្រងច្រកព្រំដែន បានផ្តាំផ្ញើដល់ អភិបាល អភិបាលរង ខេត្តជាប់ព្រំដែន ជាមួយថៃ ឡាវ និងវៀតណាម ត្រូវបន្តពង្រឹងកិច្ចសហការទំនាក់ទំនងល្អ ដើម្បីផ្លាស់ប្តូរព័ត៌មាន ជាពិសេស ពាក់ព័ន្ធរឿងបីធំៗ រួមមាន ការទប់ស្កាត់ការជួញដូរមនុស្ស គ្រឿងញៀន និងអាវុធជាតិផ្ទុះ នៅចក្រព្រំដែន កម្ពុជា ឡាវ ខេត្តស្ទឹងត្រែង។ ទាក់ទងនឹងការឆបោកតាមប្រព័ន្ធអនឡាញ (AI) ឯកឧត្តមអភិសន្តិបណ្ឌិត ក៏បានលើក ឡើងថា ធ្លាប់កើត មាននៅកម្ពុជារួចមកហើយ ដែលជាករណីឆបោកប្រាក់តាមប្រព័ន្ធអនឡាញ តែការឆបោក មនុស្សក៏អាចកើត មាននៅពេលខាងមុខបានដែរ សុំឱ្យក្រុមការងារបច្ចេកទេសពិនិត្យរឿងនេះ ដើម្បីពង្រឹងការ គ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យា ឱ្យមានប្រសិទ្ធភាព។ ផ្អែកតាមផែនការយុទ្ធសាស្ត្រជាតិ មានទស្សនវិស័យ គោលដៅ និងគោលបំណងច្បាស់លាស់ ដោយបានកំណត់នូវសូចនាករ និងលទ្ធផលតាមការរំពឹងទុកជាក់លាក់ ងាយស្រួល ក្នុងការអនុវត្ត ដូច្នេះក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវបន្តអនុវត្តតាមវិស័យខុសៗគ្នាឱ្យមានប្រសិទ្ធភាព ពិសេស ការផ្លាស់ប្តូរព័ត៌មាន ឱ្យគ្នាទៅវិញទៅមក។ ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ រាជធានី ខេត្ត មានភារកិច្ចរៀបចំផែនការសកម្មភាពលម្អិត ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ដែលជាជំហានក្នុងការអនុវត្ត ហើយចាំបាច់ត្រូវមានការគាំទ្រ និងការជំរុញលើកទឹកចិត្ត ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

ជាទីបញ្ចប់ **ឯកឧត្តមអភិសន្តិបណ្ឌិត** សុំស្នើយ៉ាងទទូចគ្រប់សមាជិក គ.ជ.ប.ជ ដែលដឹកនាំដោយ ក្រុមការងារជំនាញអន្តរក្រសួងទាំង៦ ត្រូវជួបប្រជុំគ្នាដើម្បីផ្លាស់ប្តូរព័ត៌មាន តាមដានសភាពការណ៍ និងដោះស្រាយបញ្ហា រៀងរាល់បីខែម្តង ដោយឡែកនៅថ្នាក់ក្រោមជាតិ មាន គ.រ.ប.ជ/គ.ខ.ប.ជ គប្បីរៀបចំការប្រជុំជារៀងរាល់ខែ និងដាក់បញ្ចូលនូវរបៀបវារៈសំខាន់ៗទាំងបី (ការជួញដូរមនុស្ស គ្រឿងញៀង អាវុធជាតិផ្ទុះ) ហើយអាចថែមបញ្ហាគ្រោះថ្នាក់ចរាចរណ៍មួយទៀត ដែលជារឿងចាំបាច់នាពេលបច្ចុប្បន្ន និងសុំបញ្ជូនរបាយការណ៍ឱ្យទាន់ពេលវេលាតាមការកំណត់ គឺរៀងរាល់ **ថ្ងៃ<u>ទី ២៧ ចុងខែ</u>** នីមួយៗ ដើម្បីក្រុមការងារអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បូកសរុបទាន់ពេលវេលា ហើយរបាយការណ៍របស់គណៈកម្មាធិការជាតិ ត្រូវតែមានទិន្នន័យតែមួយ ដែលចេញ ពីអគ្គលេខាធិការដ្ឋាន នៃ គ.ជ.ប.ជ ដែលទទួលស្គាល់ដោយរាជ រដ្ឋាភិបាលកម្ពុជា និងអាចប្រើប្រាស់បានជាផ្លូវការតែម្តង។

**ឯកឧត្តមអភិសន្តិបណ្ឌិត** ក៏បានមានប្រសាសន៍ថ្លែងអំណរគុណ និងជូនពរចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ឯកឧត្តម លោកជំទាវ ភ្ញៀវជាតិ អន្តរជាតិ និងអង្គពិធីទាំងមូល សូមមានសុខភាពល្អ និងសូមជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ និងពលៈ** កុំបី ឃ្លៀងឃ្លាតឡើយ។

## IV. ពិធីប្រគល់សៀវភៅផែនការយុទ្ធសាស្ត្រជាតិ

**ឯកឧត្តម អភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន **គ.ជ.ប.ជ** បានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ ផ្តល់ជូននូវសៀវភៅផែនការយុទ្ធសាស្ត្រជាតិ ឆ្នាំ២០២៤-២០២៨ ជូនដល់ឯកឧត្តម លោកជំទាវ ដែលជាអនុប្រធាន គ.ជ.ប.ជ និងជាប្រធានក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័នទាំង០៦ ដែលជាសមាជិក គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ផងដែរ។

ពិធីប្រកាសផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រជាតិ ឆ្នាំ ២០២៤-២០២៨ ស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ត្រូវបានបញ្ចប់នៅវេលាម៉ោង ដប់និងសូន្យនាទី ព្រឹក ថ្ងៃ ខែ ឆ្នាំ ដដែល ប្រកបដោយបរិយាកាសសោមនស្សរីករាយ និងស្និទ្ធស្នាលជាទីបំផុត។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូម **លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់ ។

សូម **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

ថ្ងៃសុក្រ ១៣រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ សីហា ឆ្នាំ២០២៤

**អ្នកធ្វើរបាយការណ៍**

វរសេនីយ៍ឯក.អ៊ុច ចាន់ថា

បានពិនិត្យ និងគោរពជូន
**លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ**
មេត្តាជ្រាបរបាយការណ៍ដ៏ខ្ពង់ខ្ពស់។
ថ្ងៃអង្គារ ២កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី ៦ ខែ សីហា ឆ្នាំ២០២៤

**ប្រធានលេខាធិការដ្ឋានរដ្ឋបាល សរុប**

ឧត្តមសេនីយ៍ទោ. ថោង_ឫទ្ធី

បានពិនិត្យ និងគោរពជូន
**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍**
មេត្តាជ្រាបរបាយការណ៍ដ៏ខ្ពង់ខ្ពស់។
ថ្ងៃពុធ ៣កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែ សីហា ឆ្នាំ២០២៤

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯក វេជ្ជ.ប៊ុណ្ណ សំខាន់

បានឃើញ
07/08/24

ជូ_ប៊ុនអេង